# ខ្លឹមសារ សង្ខេប
# ស្តីពី
# ច្បាប់ ស្តីពី ការរំលូតកូន

**ពាក្យគន្លឹះ** ផលប្រយោជន៍ស្ត្រី, ការទទួលខុសត្រូវរបស់គ្រូពេទ្យ

**១. គោលបំណងនៃច្បាប់**៖ ច្បាប់ ស្តីពី ការរំលូតកូន ត្រូវបានអនុម័តដោយសភា ក្នុងឆ្នាំ ១៩៩៧។ ច្បាប់នេះមានគោលបំណង កំណត់បែបបទ និងលក្ខខ័ណ្ឌបញ្ចប់គភ៌តាមវិធីវេជ្ជសាស្ត្រ (មាត្រា ១ និង ២)។

**២. ខ្លឹមសារ៖** ការរលូត ត្រូវធ្វើឡើង ដោយវេជ្ជបណ្ឌិត ឬគ្រូពេទ្យមធ្យម ឬឆ្មបមធ្យម (អ្នកទទួលបានការអនុញ្ញាត) ដែលមានការអនុញ្ញាត (មាត្រា៥) និងធ្វើនៅក្នុងទីតាំងអនុញ្ញាត ដោយក្រសួងសុខាភិបាល ដូចជា គ្លីនីក (មាត្រា ៦) មានបច្ចេកទេសក្នុងការព្យាលបាលបន្ទាន់នូវរាល់ផលវិបាកនៃការរំលូតកូន ឬ មធ្យោបាយបញ្ជូនបន្តទៅមន្ទីរពេទ្យ (មាត្រា ៦)។

ដើម្បរំលូតបានលុះត្រាតែ គភ៌ត្រូវមានអាយុមិនលើស១២សប្តាហ៍។ ករណីអាយុលើសពីនេះលុះត្រា គក៏មិនអាចលូតលាស់ដូចប្រក្រតី ឬបង្កគ្រោះថ្នាក់ដល់ជីវិតម្តាយ, កើតមកអាចមានជំងឺធ្ងន់ធ្ងរព្យាបាលមិនជា។ ក្នុងករណីរំលោភ មិនចាំបាច់គោរពតាមលក្ខខ័ណ្ឌទាំងនេះទេ តែត្រូវមានការស្នើសុំពីសាមីខ្លួន បើអាយុ១៨ឆ្នាំ ឬ ក្រោម ១៨ឆ្នាំ ត្រូវមានការទទូចសុំពីអាណាព្យាបាល និងសាមីខ្លួន (មាត្រា ៨)។

ការរំលូត ត្រូវមានការស្នើសុំ និងគ្មានការបង្ខំ(មាត្រា ៨)។ ការសម្រេចរំលូតកូន ត្រូវមានការឯកភាពពីក្រុមគ្រូពេទ្យ ២ ឬ៣រូប រួមទាំងសាមីខ្លួនផង (មាត្រា៨)។ គ្រូពេទ្យ ត្រូវពន្យល់អំពីផលវិបាកដែលអាចកើតមាន (មាត្រា ៧)។ រាល់ឯកសារទាក់ទងនឹងការរំលូតកូន ត្រូវទុកជាការសំងាត់ (មាត្រា ៩)។

ច្បាប់បានចែងអំពីទោសរួមមាន ការព្រមាន ឬការបិទទីតាំង ដាក់ពន្ធនាគារ និង ពិន័យ ចំពោះវេជ្ជបណ្ឌិតធ្វើការរំលូតកូនដោយគ្មានការអនុញ្ញាត (មាត្រា១២), រំលូតនៅទីកន្លែងមិនមានការអនុញ្ញាត (មាត្រា១២), បុគ្គលដែលមិនមានជំនាញ តែធ្វើការរំលូតកូន, អ្នកទទួលការអនុញ្ញាតតែមិនគោរពលក្ខខ័ណ្ឌចែងក្នុងមាត្រា មាត្រា៨ (មាត្រា១៣), បុគ្គលទំលាយការសំងាត់ (មាត្រា១៥), អ្នកបង្ខំឲ្យគេរំលូតកូន (មាត្រា១៤)។ ទោសដាក់ពន្ធនាគារ រហូតដល់១០ ឆ្នាំ បើការរំលូតកូននាំឲ្យមានពិការភាព ឬ ស្លាប់ដល់ស្ត្រីទទួលធ្វើរំលូតកូន (មាត្រា ១២ និង ១៤)។

**៣. លិខិតបទដ្ឋានគតិយុត្តគម្រូវផ្សេងទៀត៖** ប្រកាស របស់ក្រសួងសុខាភិបាល ស្តីពី លក្ខខ័ណ្ឌបច្ចេកទេស សម្រាប់អនុវត្តមាត្រា ៨ (មាត្រា ៨)។